ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
ក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច

សេចក្ដីប្រកាសព័ត៌មាន

## សៀវភៅម្ហូបកេរដំណែលស្នាដៃម្ហូបខ្មែរ ភាគ២ ទទួលបាន «ពានរង្វាន់ពិសេសរបស់គណៈវិនិច្ឆ័យ»

សៀវភៅម្ហូប **«កេរដំណែលស្នាដៃម្ហូបខ្មែរ ភាគ២»** ដែលរៀបចំ និងចងក្រងដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួល **«ពានរង្វាន់ពិសេសរបស់គណៈវិនិច្ឆ័យ»** ( Special Award of the Jury )ពី Gourmand Awards លើកទី៣០ នៅក្នុងកម្មវិធី Cascais World Food Summit ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៨-២២ ខែមិថុនា ឆ្នាំ២០២៥ នៅទីក្រុងលីសស្បោន ប្រទេសព័ទុយហ្គាល់ ដោយមានអ្នកចូលរួមរាប់រយនាក់ មកពីប្រមាណ ២០០ប្រទេស។

សៀវភៅ «កេរដំណែលស្នាដៃម្ហូបខ្មែរ ភាគ២» ត្រូវបានប្រកាសចេញផ្សាយជាផ្លូវការ ដោយ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៥ ក្នុងគោលបំណងបន្តផ្សព្វផ្សាយ និងលើកកម្ពស់កេរដំណែលសិល្បៈម្ហូបខ្មែរដែលជាផ្នែកមួយនៃយុទ្ធនាការការទូតអាហារ ក៏ដូចជាការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចរបស់កម្ពុជា។

សៀវភៅម្ហូបនេះ ត្រូវបានផ្តួចផ្តើមរៀបចំឡើងបន្ទាប់ពីភាពជោគជ័យដ៏ត្រចះត្រចង់របស់សៀវភៅ «កេរដំណែលស្នាដៃម្ហូបខ្មែរ» ដែលទទួលបានពានរង្វាន់អន្តរជាតិចំនួន ៤ រួមមាន «សៀវភៅម្ហូបអាស៊ីល្អដាច់គេ» ឆ្នាំ២០២១ និង ឆ្នាំ២០២២ «សៀវភៅម្ហូបឆ្នើមដែលរៀបរៀងដោយថ្នាក់ដឹកនាំនៃរដ្ឋ» ឆ្នាំ២០២២ និង «ពាន់រង្វាន់ទូរទស្សន៍ម្ហូបអាហារល្អដាច់គេលើពិភពលោក» ឆ្នាំ២០២៣។

សៀវភៅ **«កេរដំណែលស្នាដៃម្ហូបខ្មែរ ភាគ២»** បានចងក្រងមុខម្ហូប និងបង្អែមខ្មែរចំនួន ៣៨មុខ ដែលជាទីពេញនិយមរបស់ប្រជាជនខ្មែរទូទៅ។ សៀវភៅនេះក៏បានរំលេចផលិតផលកសិកម្ម និងទទួលបានម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់កម្ពុជារួមមាន អង្ករផ្កាម្លិះ ម្រេចកំពត អំបិលកំពត-កែប និងស្ករត្នោតកំពង់ស្ពឺ ជាដើម។

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ: (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

លោក Edouard Cointreau ប្រធានគណៈកម្មាធិការកម្មវិធីពានរង្វាន់ បានលើកឡើងថា «កិច្ចខិតខំប្រឹងប្រែងដ៏ធំធេងរបស់ក្រសួងការបរទេសនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងអំឡុងប៉ុន្មានឆ្នាំចុងក្រោយនេះ បានជំរុញឱ្យពិភពលោកចាប់ផ្តើមសិក្សាស្វែងយល់ពីប្រជាជនខ្មែរឡើងវិញ ជាមួយផ្នត់គំនិតដែលកម្រនឹងមានពីមុនមក គឺការកែលម្អ និងលើកកម្ពស់សិល្បៈម្ហូបខ្មែរ។ សៀវភៅភាគ២ នេះ ប្រមូលផ្តុំនូវការសិក្សាដ៏គួរឱ្យទាក់ទាញ ដែលលើកតម្កើងអតីតកាលដ៏រុងរឿង សាទរយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពនាបច្ចុប្បន្នកាល និងទន្ទឹងរង់ចាំអនាគតកាលដ៏ត្រចះត្រចង់របស់ប្រទេសកម្ពុជា»។

ពានរង្វាន់មួយនេះ គឺជាសមិទ្ធផលថ្មីមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចបន្តខិតខំប្រឹងប្រែងចូលរួមលើកកម្ពស់កិត្យានុភាពជាតិ និងដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជាក្នុងការប្រែក្លាយជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០ តាមរយៈការផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រ វប្បធម៌ និងទំនៀមទម្លាប់ដ៏ល្អផូរផង់របស់កម្ពុជា។

ថ្ងៃ ព្រហស្បតិ៍ ៩រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៥